**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

លេខ:០០៥/០៩កហ.អគគ

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩*

# កំណត់ហេតុស្តីពី កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីរពាន់ប្រាំបួន ខែ កុម្ភៈ ថ្ងៃទី ២៣ វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសណ្ឋាគារសាន់វ៉េ មាន រៀបចំកិច្ចប្រជុំលើកដំបូងសំរាប់ឆ្នាំ២០០៩ របស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្រោមអធិបតីភាព របស់ឯកឧត្តម ស៊ិយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោងនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីពិនិត្យពិភាក្សាលើការបន្តការងាររបស់ខ្លួនក្នុងឆ្នាំថ្មី ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស៊ិយ ម៉ុងលាង បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៃក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះក្នុងថ្ងៃនោះ។ ក្នុងឱកាសនោះដែរ ឯកឧត្តមបានជម្រាបជូនអង្គប្រជុំទាំងមូលថា ឯកឧត្តម សំ សុខផល មានមុខងារជា រដ្ឋលេខាធិការនៅក្រសួងយុត្តិធម៌ ហើយចំពោះក្រុមការងារបច្ចេកទេសចម្រុះ ឯកឧត្តមផ្ទាល់ជាអ្នកគ្រប់គ្រងបន្តពី ឯកឧត្តម សំ សុខផល ។ ជាបន្ទាប់ឯកឧត្តម ប្រធានបានជម្រាបជូនអំពីវឌ្ឍនភាពនៃការអនុវត្តសូចនាករ តាមដានរួម កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជូនអង្គប្រជុំដូចខាងក្រោម:

-ក្រមព្រហ្មទណ្ឌត្រូវបានឆ្លងអន្តរក្រសួង ហើយបច្ចុប្បន្នកំពុងរៀបចំដាក់ជូនគណៈរដ្ឋមន្ត្រី

-សេចក្តីព្រាងច្បាប់អង្គការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ និងសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម ច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតនៅក្នុងដៃក្រសួងយុត្តិធម៌។

-

សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយបច្ចុប្បន្នកំពុងត្រូវបានពិនិត្យដោយអង្គភាពប្រឆាំងអំពើពុករលួយ

-សេចក្តីណែនាំស្តីពីការតាក់តែងច្បាប់បានឆ្លងកិច្ចប្រជុំលើកទី១រួច និងបច្ចុប្បន្នត្រៀមដាក់ប្រជុំអន្តរ ក្រសួង ។

-ទីប្រឹក្សាគម្រោង CCJAP ម្នាក់បានជួយតុលាការខេត្តកណ្តាល ក្នុងការរៀបចំបែបបទសំរាប់ចុះបញ្ជីសំណុំ រឿងព្រហ្មទណ្ឌ ហើយបច្ចុប្បន្នកំពុងសាកល្បងនៅតុលាការខេត្តកណ្តាល។

**របាយការណ៍ស្តីពីវឌ្ឍនភាពរបស់អនុក្រុមការងារបច្ចេកទេសចម្រុះ**

ឯកឧត្តមប្រធានបានមានប្រសាសន៍ថា ទោះបីជាអនុក្រុមមិនបានប្រជុំក្តី ក៏សកម្មភាពកំណែទម្រង់ច្បាប់ និង តុលាការ នៅតែមានដំណើរទៅមុខគួរឱ្យកត់សំគាល់:

១- ទិន្នន័យស្តីពីការបណ្តុះបណ្តាលសិទ្ធិមនុស្ស (មាន Rights Training Database)- ទិន្នន័យនេះត្រូវបាន រៀបចំបង្កើតឡើង ដោយអង្គភាពគ្រប់គ្រងគម្រោង ប៉ុន្តែទាមទារឱ្យមានការដាក់បញ្ចូលទិន្នន័យផងដែរ។ បច្ចុប្បន្នកំពុង ស្វែង រកថវិកាសម្រាប់បន្តការងារ និងការស្ទង់មតិមូលដ្ឋានអំពីការបណ្តុះបណ្តាលសិទ្ធិមនុស្សនេះ ។

២- ឯកសារពិគ្រោះយោបល់ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការចូលរួមចំណែករបស់ សង្គមស៊ីវិល ចំពោះការអនុវត្តន៍ កំណែទម្រង់បាននឹងកំពុងរៀបចំឡើងដោយសហការជាមួយ DIHR។ ឯកសារនេះនៅជាសេចក្តីព្រាងនៅឡើយ ប៉ុន្តែត្រូវបានរំពឹងថានឹងអាចបញ្ចប់ក្នុង រយៈពេលបីខែខាងមុខ។

៣- ច្បាប់អង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័ត។

៤- ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃបានសហការអនុវត្តគម្រោងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។ មណ្ឌលសេវាកម្មយុត្តិធម៌ចំនួន២០ត្រូវបានបង្កើតឡើងនៅថ្នាក់ស្រុក ហើយគណៈកម្មាធិការដោះស្រាយវិវាទ ចំនួន៨០ ត្រូវបានបង្កើត ឡើងនៅថ្នាក់ឃុំ។

៥- ប្រព័ន្ធសូចនាករតាមដានកំណែទម្រង់ច្បាប់ និងតុលាការត្រូវបានបង្កើតឡើង ហើយវិធីសាស្រ្តសម្រាប់ វាស់វែងការអនុវត្តន៍សកម្មភាពត្រូវបានអនុម័តដោយក្រុមការងារជាន់ខ្ពស់

របស់គម្រោង ។ នៅពេលខាងមុខ DIHR និង PMU នឹងចាប់ផ្តើមអនុវត្តការវាស់វែងនេះ នៅតុលាការគំរូខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និងតុលាការ រាជធានីភ្នំពេញ។

លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម បានធ្វើការបង្ហាញ អំពីការរៀបចំ របាយការណ៍ស្តីពីសកម្មភាពដៃគូអភិវឌ្ឍន៍នៅក្នុង (កកចយ) ដែលជាការឧបត្ថម្ភគាំទ្ររបស់ JICA តាមរយៈការបញ្ចាំងស្លាយ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានធ្វើការកត់សំគាល់ថាការបង្ហាញនេះ ឆ្លុះបញ្ចាំងឱ្យឃើញថាការកែទម្រង់កំពុង ធ្វើដំណើរនៅពាក់កណ្តាលផ្លូវនៃដំណាក់កាលអនុវត្តន៍ ប៉ុន្តែទាំងដៃគូអភិវឌ្ឍន៍ ព្រមទាំងរាជរដ្ឋាភិបាល បានទទួលស្គាល់ថា វាស្ថិតនៅឆ្ងាយនៅឡើយពីទិសដៅនៃកំណែទម្រង់ច្បាប់ និងតុលាការ។ ការបង្ហាញក៏បានលើកឡើងនូវបញ្ហាមួយចំនួន ដោយហេតុថា ច្បាប់ជាមូលដ្ឋានមួយចំនួនធំត្រូវបានអនុម័ត ប៉ុន្តែទាមទារនូវការអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ហើយ តុលាការគំរូកំពុងត្រូវបានរៀបចំ ប៉ុន្តែទាមទារឱ្យមានការអនុវត្តន៍សកម្មភាពជាក់ស្តែងមួយចំនួន មុននឹងការផ្លាស់ប្តូរណាមួយ កើតឡើង ។ ឯកឧត្តមប្រធានបានឯកភាពចំពោះការលើកឡើងនេះ ដែលនឹងត្រូវពិភាក្សានៅពេលក្រោយទៀត ។

តំណាង JICA បានសម្តែងការអរគុណចំពោះបទបង្ហាញរបស់លោក ឃ្លោក ដារ៉ា ហើយបានជម្រាបជូនថា នេះគឺ ជាលើកដំបូងហើយដែលបានឃើញរបាយការណ៍ ក្បោះក្បាយដូច្នេះ។ របាយការណ៍នឹងរឹតតែប្រសើរឡើងថែមទៀត ប្រសិនបើមានរៀបរាប់លំអិតនូវសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ។ ការផ្សារភ្ជាប់ទំនាក់ទំនងរវាងរបាយការណ៍ នេះ និងប្រព័ន្ធសូចនាករតាមដាន ( IMS) គឺជា ការប្រសើរ ហើយ JICA នឹងជួយគាំទ្រសកម្មភាពនេះ។ JICA ក៏បានកត់សំគាល់ទៀតដែរថា នៅក្នុងរបាយការណ៍ត្រូវមានកត់សំគាល់អំពីគម្លាត និងប្រភពធនធានដៃគូអភិវឌ្ឍន៍ ប៉ុន្តែ គេគួរទាក់ទងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិន ព្រោះការអនុវត្តន៍មិនមែនតែជាការទទួលខុសត្រូវ របស់ដៃគូអភិវឌ្ឍន៍ តែម្នាក់ឯងនោះទេ។

តំណាង GTZ កត់សំគាល់ឃើញថា របាយការណ៍បានរៀបរាប់សកម្មភាពជាច្រើន ដែលដាក់ថាគាំទ្រដោយ GTZ ប៉ុន្តែមិនបានឆ្លុះបញ្ចាំងអំពីទំហំទឹកប្រាក់ ឬធនធានផ្សេងទៀត នោះទេ ។ សកម្មភាពមានជាច្រើន គឺដោយសារតែពាក់ព័ន្ធ នឹងកំណែទម្រង់រដ្ឋបាល ដូច្នេះ គេគួរតែបង្ហាញផងដែរនូវភាពពាក់ព័ន្ធនេះ។

តំណាងប្រទេសបារាំងបានសម្តែងការអរគុណចំពោះ លោក ឃ្លោក ដារ៉ា ចំពោះការបង្ហាញ ហើយបានកត់ សំគាល់ថា លំហាត់នេះ គឺជាចំណុចចាប់ផ្តើម ហើយត្រូវការធ្វើបច្ចុប្បន្នភាពជាប្រចាំ។

តំណាង AusAid បានថ្លែងអំណរគុណចំពោះ PMU ទាំងមូល ចំពោះការបង្ហាញ ហើយបានរៀបរាប់អំពីទិន្នន័យ ប្រហាក់ប្រហែលនេះនៅ CDC ដែលអាចយកមកប្រើបានដែរ។ បើមិនដូច្នោះទេ អាចទាមទារឱ្យមានការធ្វើការស្ទង់មតិ មួយឡើង។ AusAid ក៏បានលើកជាសំណួរឡើងអំពីការផ្សារភ្ជាប់គ្នារវាងកំណែទម្រង់ច្បាប់ និងតុលាការ និងកំណែ ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ឧទាហរណ៍ថា តើក្រុមប្រឹក្សាខេត្តមានតួនាទីនៅក្នុងកំណែទម្រង់ច្បាប់ និងតុលាការ ដែរឬទេ? ហេតុនេះគួរតែមានការចែករំលែកពត៌មានរវាងកំណែទម្រង់ច្បាប់ និងតុលាការ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

តំណាង DANIDA បានជម្រាបជូនថា ការស្ទង់មតិនឹងផ្តល់ឱកាសពិនិត្យមើលទិសដៅជាយុទ្ធសាស្ត្រទាំងប្រាំពីរ ហើយអាចឱ្យយើងមើលឃើញថាតើ យើងដើរដល់ណាហើយក្នុងការសំរេចទិសដៅទាំងនោះ។

ឯកឧត្តមប្រធានបានមានប្រសាសន៍ថា បញ្ហាមួយចំនួនត្រូវដោះស្រាយឱ្យបានមុនពេលឈានដល់ការសំរេច ។ រាជរដ្ឋាភិបាលកំពុងតែសាកល្បងអនុវត្តគ្រប់សកម្មភាពទាំង៩៧ ដូច្នេះមានសកម្មភាពខ្លះទាមទារនូវការគិតគូបន្ថែមទៀត ។

**ការអនុវត្តន៍ និងការតាមដានតុលាការគំរូ**

លោក គង់ ផល្លៈ បង្ហាញអំពីវឌ្ឍនភាពនៃគម្រោងតុលាការគំរូតាមរយៈការបញ្ចាំងស្លាយ

ឯកឧត្តមប្រធានបានជំរាបអង្គប្រជុំថា ដំណាក់កាលនៃការអនុវត្តន៍គម្រោងតុលាការគំរូនឹងត្រូវប្រគល់ជូនក្រសួង យុត្តិធម៌ ។

លោក គង់ ផល្លៈ ជំរាបអង្គប្រជុំថា សំណួរចំពោះតុលាការគំរូចែកចេញជា ការគ្រប់គ្រងរឿងក្តី រដ្ឋបាល- តុលាការ និងការគ្រប់គ្រងតុលាការ ដោយមានសរុបចំនួន៥៣ដែល

ត្រូវពិចារណា ។ បន្ទាប់មកក៏មានការបង្ហាញ សំណួរ ហើយ PMU បានពន្យល់ជូនអង្គប្រជុំអំពីការបង្កើត និងការប្រើបញ្ជីសំណួរ។

តំណាង DANIDA កត់សំគាល់ថា ការកំណត់ចំណាយមានលក្ខណៈសំខាន់ខ្លាំងណាស់ ហើយទាមទារឱ្យមាន ការរៀបចំឡើង។ នៅក្នុងបញ្ហានេះ ឯកឧត្តមប្រធានតុលាការបានបញ្ជាក់ថា បច្ចុប្បន្នកំពុងអនុវត្តលើការងារនេះហើយ។

**ការសិក្សាអំពីមុខងារ និងការពិនិត្យយុទ្ធសាស្ត្រ ចំពោះក្រសួងយុត្តិធម៌**

តំណាង AusAID បានជំរាបអង្គប្រជុំថា នៅក្នុងកិច្ចប្រជុំក្រៅផ្លូវការនៃក្រុមអ្នកផ្តល់ជំនួយដៃគូអភិវឌ្ឍន៍ បានពិចារណាលើការជួយរៀបចំផែនការយុទ្ធសាស្ត្រក្រសួងយុត្តិធម៌ និងអនុវត្តការសិក្សាអំពីមុខងារ និងតម្រូវការធនធាន មនុស្សរបស់ក្រសួងនេះ។ ធ្វើដូច្នេះនឹងជួយឱ្យកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធខ្លាំងឡើងថែមទៀតរវាងដៃគូអភិវឌ្ឍន៍ និងក្រសួងយុត្តិធម៌។

ខាង AusAid កត់សំគាល់ថា ដៃគូអភិវឌ្ឍន៍ផ្សេងទៀតក៏មានការគាំទ្រដល់ក្រសួងយុត្តិធម៌ផងដែរ ហេតុដូច្នេះ ការផ្តល់មតិយោបល់របស់គេទាក់ទងនឹងដំណើរការនេះ គឺជាការប្រសើរ។ AUSAID និង Danida បានព្រមព្រៀង ចាប់ផ្តើមដំណើរការនេះ ប៉ុន្តែទាមទារនូវការពិគ្រោះយោបល់បន្ថែមជាមួយដៃគូអភិវឌ្ឍន៍នានា ។ AusAID បានជំរាប អង្គប្រជុំថា ខ្លួនបានជួបជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយឯកឧត្តមរដ្ឋមន្ត្រីបានសំដែងនូវការពេញចិត្តចំពោះការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ដល់ដំណើរការនេះ។

ឯកឧត្តមប្រធានបានសុំឱ្យក្រសួងយុត្តិធម៌មានយោបល់ជុំវិញបញ្ហាខាងលើ ប៉ុន្តែតំណាងក្រសួងយុត្តិធម៌ដែលបាន អញ្ជើញមកចូលរួមប្រជុំបានជម្រាបជូនអង្គប្រជុំថា មិនបានដឹងរឿងអស់នេះទេ ហើយនឹងញុំនាំពត៌មានទាំងនេះទៅរាយការណ៍ ជូនថ្នាក់ដឹកនាំ ។

ខាង CCJAP ជំរាបអង្គប្រជុំថា ខ្លួនកំពុងរៀបចំធ្វើផែនការសម្រាប់រយៈពេល៦ខែ ចាប់ពីខែកក្កដា ដល់ខែធ្នូ ដើម្បីតំរឹមជាមួយផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយរួមបញ្ចូលទាំងធនធានដែលនឹងត្រូវអនុវត្តសម្រាប់រៀបចំ ផែនការយុទ្ធសាស្ត្រ និងសិក្សាអំពីមុខងាររបស់ក្រសួងយុត្តិធម៌ផងដែរ។ អាចនឹងមានការគាំទ្រផងដែរដល់ការធានាឱ្យ មាននូវប្រព័ន្ធ

រដ្ឋបាលតុលាការ ការគាំទ្រតុលាការគំរូផ្សេងៗ និងការតាមដាន និងការវាយតម្លៃ ដើម្បីទ្រទ្រង់ដល់ការបោះ ជំហានទៅមុខនៃការអនុវត្តន៍តុលាការគំរូ។ ក្នុងនោះដែរក៏មានការកត់សំគាល់ទៀតថា ការចូលរួមក្នុងកំរិតខ្ពស់របស់ ក្រសួងយុត្តិធម៌ត្រូវការឱ្យមានជាចាំបាច់ ដើម្បីបញ្ជាក់អំពីឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍តុលាការគំរូ។

ខាង JICA យល់ឃើញថា នេះជាគំនិតល្អ ព្រោះក្រសួងយុត្តិធម៌គឺជាក្រសួងគន្លឹះក្នុងការអនុវត្តន៍គម្រោង ប៉ុន្តែ ទាមទារឱ្យមានធនធាន និងថវិកាកាន់តែច្រើនថែមទៀតសម្រាប់ការអភិវឌ្ឍន៍ទៅមុខនៅក្នុងក្រសួង ហើយដៃគូអភិវឌ្ឍន៍ ធ្លាប់មានបទពិសោធន៍ចំពោះបញ្ហាប្រឈម ដោយសារតែកង្វះធនធានទាំងនេះ ។ ប្រការសំខាន់គេមិនគួរដាក់បន្ទុកខ្លាំងពេកលើក្រសួងយុត្តិធម៌ ដូច្នេះដៃគូអភិវឌ្ឍន៍ត្រូវតែសហការគ្នា។

ខាង DANIDA ស្នើក្រសួងយុត្តិធម៌ផ្តល់ជូនដៃគូអភិវឌ្ឍន៍នូវការសុំជំនួយដោយមានសរសេរជាលាយលក្ខណ៍អក្សរ ។ ហើយក៏មានការកត់សំគាល់ផងដែរថា ក្នុងរយៈពេល២សប្តាហ៍ទៀតនេះ DIHR នឹងចាប់ផ្តើមអនុវត្តការសិក្សានៅ តាមបណ្តាខេត្តដែលមានតុលាការគំរូ ដើម្បីពិនិត្យមើលរបៀបនៃការពិភាក្សាជាមួយសង្គមស៊ីវិល ព្រោះសង្គមស៊ីវិល ធ្លាប់មានបទពិសោធន៍លើការតាមដាន។

ខាង UNICEF ពេញចិត្តក្នុងការចូលរួមចំណែក ហើយស្នើឱ្យមានការពិគ្រោះយោបល់រវាងដៃគូអភិវឌ្ឍន៍នានា ដើម្បីពិនិត្យមើលដំណើរការនៃការពង្រឹងស្ថាប័នទាំងមូល ហើយកុំឱ្យមានផលប្រយោជន៍ផ្ទាល់ខ្លួនគ្របដណ្តប់ច្រើនខ្លាំងពេក ។

ខាង JICA យល់ស្របជាមួយ UNICEF ប៉ុន្តែចង់ដឹងពីយោបល់របស់ក្រសួងយុត្តិធម៌ ដើម្បីទាមទារ នូវកិច្ចខិតខំប្រឹងប្រែងរួម ហើយក៏ចង់ដឹងអំពីយោបល់ពីអ្នកពាក់ព័ន្ធ ផ្សេងៗទៀតនៅក្នុងក្រសួងយុត្តិធម៌ផងដែរ មិន ត្រឹមតែរដ្ឋមន្ត្រីប៉ុណ្ណោះទេ ។

ខាង UNDP បានជំរាបអង្គប្រជុំអំពីការវាយតម្លៃហិរញ្ញវត្ថុក្រសួងយុត្តិធម៌ ដែលត្រូវបានអនុវត្តដោយ KPMG កាលពីឆ្នាំកន្លងទៅ។ អនុសាសន៍មួយចំនួនទាក់ទងនឹងរចនាសម្ព័ន្ធហិរញ្ញវត្ថុមានដាក់នៅក្នុងរបាយការណ៍ស្រាប់ ។

**កិច្ចការផ្សេងៗ**

សហាគមន៍អឺរ៉ុបបានជំរាបអង្គប្រជុំថា គេរំពឹងថានឹងចុះហត្ថលេខាផ្តល់ជំនួយគាំទ្រសកម្មភាពកំណែទម្រង់នៅខែក្រោយ ។

ខាងក្រសួងកិច្ចការនារីបានថ្លែងអំណរគុណឯកឧត្តមប្រធានចំពោះការបង្ហាញជូននូវសកម្មភាពម្ចាស់ជំនួយ ជា ពិសេស GTZ ជាដៃគូដ៏ល្អ ដែលបានជួយលើជំនួយផ្នែកច្បាប់ និងការរៀបចំច្បាប់។ ក្រសួងកិច្ចការនារីជំរាបជូនអង្គ ប្រជុំថា ផែនការឆ្នាំ២០០៩ ក្រសួងនឹងស្នើសុំគម្រោងបីៈ

១-ច្បាប់ការងារត្រូវបានអនុម័តឆ្នាំ១៩៩៧ ប៉ុន្តែទិដ្ឋភាពមួយចំនួនទាក់ទងនឹងតម្រូវការដែលត្រូវដោះស្រាយ ជាពិសេសទាក់ទងនឹងការងារតាមផ្ទះពុំទាន់ឆ្លើយតបនឹងការជាក់ស្តែង នៅឡើយ ។ ហេតុនេះក្រសួងកិច្ចការនារីមានចំណាប់ អារម្មណ៍ក្នុងការធ្វើវិសោធនកម្មច្បាប់នេះ ។

២-ចំពោះការជួញដូរមនុស្ស-មានចំណុចខ្វះចន្លោះខ្លះនៅក្នុងច្បាប់ ហើយផ្នែកខ្លះមានលក្ខណៈមិនស្របគ្នាជាមួយ ក្រមព្រហ្មទណ្ឌ ។ ក្រសួងកិច្ចការនារីចង់ដឹងតើច្បាប់ណាមួយដែលត្រូវកែសម្រួល ។

៣-ច្បាប់ដីធ្លី-ទាក់ទងនឹងការបែងចែកដីធ្លី និងការអនុវត្តន៍ច្បាប់ ។ បញ្ហាដែលស្ត្រីក្រីក្រមិនអាចទទួលផល ប្រយោជន៍ពីច្បាប់នេះ។ មានមាត្រាខ្លះក្នុងច្បាប់នេះត្រូវកែប្រែ ដើម្បីឱ្យស្ត្រីក្រីក្រអាចទទួលបានផលប្រយោជន៍ពីច្បាប់នេះ ។

ខាងក្រសួងកិច្ចការនារី បានអរគុណឯកឧត្តមប្រធានចំពោះការរៀបចំតុលាការ គំរូរហូតមកដល់ពេលនេះ ដើម្បី ឱ្យតុលាការផ្សេងទៀតអាចចំលង និងអនុវត្តតាមទម្លាប់ល្អបំផុត ។ បច្ចុប្បន្នសមត្ថភាព និងធនធានមនុស្សនៅតុលាការ នៅមានកំរិតនៅឡើយ ។ ជូន កាលស្ត្រីក្រីក្រមិនយល់អំពីនីតិវិធី ហើយខ្វះលុយធ្វើដំណើរអាចបង្កជាបញ្ហាសម្រាប់ពួកគាត់ ហើយក៏មានបញ្ហានៃការមិនបានទទួលពត៌មាន ដូច្នេះពួកគាត់មិនច្បាស់ថាតើត្រូវធ្វើដូចម្តេចនោះឡើយ ។ ឧទាហរណ៍ គាត់មិនដឹងអំពីរបៀបប្តឹងឧទ្ធរណ៍ ឬត្រូវដាក់ពាក្យបណ្តឹងយ៉ាងណានោះឡើយ។ ដូច្នេះត្រូវពិនិត្យដំណើរការនេះឱ្យបាន លឿនសម្រាប់ជនក្រីក្រ ព្រោះពួកគាត់ខ្វះមធ្យោបាយក្នុងការតាមដានសំណុំរឿង ដោយប្រើធនធានរបស់គាត់ផ្ទាល់ ។ ក្នុងពេលនោះផងដែរ ក្រសួងកិច្ចការនារីស្នើក្រសួងយុត្តិធម៌ពិនិត្យបណ្តឹងដែលក្រសួងកិច្ចការនារីបានដាក់ជូន ។ ក្រសួងកិច្ចការនារីដឹងថា មានបណ្តឹងមួយចំនួនដែលបញ្ជូនទៅក្រសួងយុត្តិធម៌ ប៉ុន្តែនៅមិនទាន់ចាត់ការនៅឡើយ។ ដូច្នេះក្រសួង កិច្ចការនារីបានស្នើសុំក្រសួងយុត្តិធម៌ឱ្យពិនិត្យលើករណីទាំងនេះ ។

ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោងបានជំរាបអង្គប្រជុំថា ក្រុមប្រឹក្សាកំណែទម្រង់ នីមួយៗ ដែលសរុបទាំងអស់មានចំនួន១៩ មានក្រុមការងារបច្ចេកទេស ចំរុះមួយដែលត្រូវសម្របសម្រួល ជាមួយក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC) ។ ដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងអនុវត្តសេចក្តីថ្លែងការណ៍ទី ក្រុងប៉ារីស ស្តីពីប្រសិទ្ធភាព ជំនួយ និងផែនការ សកម្មភាពទីក្រុងអាក្រា។ ដើម្បីជំរុញសុខដុមនីយកម្មនោះក្រុមការងារ បច្ចេកទេសចំរុះនីមួយៗត្រូវមានផែនការសកម្មភាព ។ បញ្ហាប្រសិទ្ធភាពជំនួយសម្រាប់ក្រុម ការងារបច្ចេកទេសចំរុះ នៅ មិនទាន់មានយន្តការច្បាស់លាស់នៅឡើយ ។ កាលពីឆ្នាំកន្លងទៅ CDC បានពិនិត្យមើលអំពីបញ្ហាប្រឈមនៃសមត្ថភាព ធនធានមនុស្ស ដែលជាឧបសគ្គដល់ ការកសាងនូវភាពជាម្ចាស់ និងជំរុញប្រសិទ្ធភាពជំនួយ ។ ដូច្នេះក្រុមការងារ បច្ចេកទេសចំរុះ នីមួយៗ ត្រូវបង្កើតផែនការសកម្មភាពរៀងៗខ្លួន ។ នៅពេលអនាគត CDC នឹងរៀបចំបង្កើត យន្តការរួម មួយដែលនឹងជំរុញប្រសិទ្ធភាពជំនួយ ។

តំណាងបារាំងបានជំរាបជូនអង្គប្រជុំថា ខ្លួនបានធ្វើជាសហអ្នកសម្របសម្រួល ក្នុងក្រុម ការងារបច្ចេកទេសចម្រុះ អស់រយៈពេល៥ឆ្នាំមកហើយ ដូច្នេះនៅពេលនេះ ចង់ផ្តល់តួនាទី ទៅដៃគូផ្សេងទៀត ។ ទាក់ទងនឹងការផ្ទេរនេះនៅមិន ទាន់មាននីតិវិធីនៃ ការផ្ទេរជាផ្លូវការ នៅឡើយ ប៉ុន្តែបញ្ហានេះនឹងត្រូវសំរេចនៅពេលពិធីពិសារអាហារពេលល្ងាចក្រៅផ្លូវការ របស់ដៃគូ អភិវឌ្ឍន៍នៅលើកក្រោយ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានថ្លែងអំណរគុណតំណាងកិច្ចសហប្រតិបត្តិការ បារាំងចំពោះការទទួលខុសត្រូវ រយៈពេល៥ឆ្នាំកន្លងមកនេះ ហើយសំដែងនូវការកោតសរសើរ ចំពោះជំនួយ និងចំពោះការខិតខំក្នុងការងារកំណែទម្រង់ នេះ ។ ឯកឧត្តមប្រធាន បានរំលឹក អង្គប្រជុំ អំពីជោគជ័យនៅក្នុងការអនុម័តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ការបង្កើត រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ព្រមទាំងជំនួយផ្សេងៗទៀត ។ រាជរដ្ឋាភិបាលកម្ពុជា សូម វាយតម្លៃខ្ពស់ចំពោះ ការផ្តល់ជំនួយនេះ ។ ឯកឧត្តមប្រធានបានរំលឹកទៀតថា ទោះបីជាបារាំង ដកខ្លួនពីតួនាទីជាសហអ្នកសម្របសម្រួលក្តី ក៏នៅតែចូលរួមក្នុងកំណែទម្រង់ដដែល ។

ខាងបារាំងបានជំរាបអង្គប្រជុំថា ខ្លួនគ្រាន់តែដកខ្លួនចេញពីតួនាទីសហ អ្នកសម្រប សម្រួលប៉ុណ្ណោះ ប៉ុន្តែនៅតែ ចូលរួមក្នុងសកម្មភាពកំណែទម្រង់ច្បាប់នេះដដែល ។

ឯកឧត្តមប្រធានបានមានប្រសាសន៍ថា ដៃគូអភិវឌ្ឍន៍មួយផ្សេងទៀតនឹងត្រូវបានស្នើ ឱ្យដើរតួនាទីនេះជំនួសបារាំង វិញ ហើយឯកឧត្តមបានស្នើឱ្យដៃគូអភិវឌ្ឍន៍លើកសំណើជា

លាយលក្ខណ៍អក្សរលំអិតមួយ ទាក់ទងនឹងជំនួយសម្រាប់ ក្រសួងយុត្តិធម៌ ហើយបន្ទាប់មកនឹងមានការជួបប្រជុំមួយរវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាមួយនឹងក្រសួងយុត្តិធម៌ ។ ចំពោះព្រឹត្តិបត្រ ក.ក.ច.យ ឯកឧត្តមបានជម្រាបថា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធ យុត្តិធម៌បានបោះពុម្ពរួចហើយ នឹងត្រូវចែកផ្សាយក្នុងពេលឆាប់ៗខាងមុខនេះ ។ ឯកឧត្តមបានថ្លែងអំណរគុណដល់ DANIDA ចំពោះការជួយគាំទ្រតាមរយៈមូលនិធិបត់បែន អនុវត្តដោយ CCJAPIII ។

ទីបញ្ចប់ ឯកឧត្តម ស៊ុយ ម៉ុងលាង បានថ្លែងអំណរគុណជាថ្មីចំពោះអង្គប្រជុំទាំងមូល និងសម្រេចថា ថ្ងៃប្រជុំ បន្ទាប់គឺ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៩ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោង៤ និង៥០ នាទីល្ងាចនាថ្ងៃដដែល ។

**បានឃើញ និងឯកភាព**
**នាយកអង្គភាពគ្រប់គ្រងគម្រោង** **អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង** **សេង វ៉ាន់ដា**

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
នាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

០១-ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០២-ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៣-ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៤- ឯកឧត្តម ប្រុក សារឿន ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ
០៥- ផាន់ ចន្ទ័លី អនុប្រធាននាយកដ្ឋាន ក្រសួងយុត្តិធម៌
០៦- លោក ជ សៀកវេង CCJAPIII
០៧-លោក ជឹង ផេងស្រួយ ប្រធានក្រុមគម្រោងបណ្ណ័សារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
០៨- លោក យឹម សារី តំណាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងសុក្រឹត្យការមេធាវី
០៩-លោក Ben Schultz, Adviser (CCJAP III)
១០-លាវ ពិសិដ្ឋ ក្រសួងយុត្តិធម៌
១១-ះនេង Sokheang, ACU
១២-ធរសេសលៀន Dominique, EWMI
១៣-ំ។ះៀឹលតេត្យ EWMI
១៤- Yuki Wakasuji, Embassy of Japan
១៥- Sun Samnang, EWMI
១៦-គហោានង Seng, AGU
១៧-ំៀមៀកៀ Hotta (Assistant Resident Representative, JICA )
១៨-ហ៊ូ ស្ថាបនា មន្ត្រី ACU
១៩-្រៀស Chhay, AusAid
២០-ឡសេលយេ Miller ( UNICEF Chief Child Protection )
២១-ភហៀន Samphors, CADB/CDC
២២-ំិចហាលេ Engquist, Senior Program Officer
២៣-ភៀក Phira, Staff, Jica
២៤-ឡិសេ Dahl, UNDP
២៥-គាតហារិនា Hubner, GTZ
២៦-លោកស្រី ស្រី ប៊ុណ្ណារ័ត្ន អនុប្រធានក្រុមគម្រោងបណ្ណ័សារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ

២៧-លោកស្រី សេង វ៉ាន់ដា មន្ត្រី ក.ក.ច.ន.យ

២៨-លោក សម តារា អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ

២៩-លោកស្រី សាខឿន សាវ៉ាត់ឌី ក្រសួងកិច្ចការនារី

៣០-លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

៣១-កញ្ញា ផាន់ ពីសីនលក្ខណ៍ មន្ត្រី ក.ក.ច.ន.យ

៣២-លោក ហូ ភត្រា មន្ត្រី ក.ក.ច.ន.យ

៣៣-លោកស្រី ឈូក សារ៉ុម ប្រធានការិយាល័យ

៣៤-្របហាមិលា Unnicrishnan, Human rights officer, Rule of Law(OHCHR)

៣៥-្រេៀនង Vaunsin, EC

៣៦-េាលាន Mccagh, Team Leader (CCJAP)

៣៧-ះេៀនយេ Sokry, Office Manager( UsAID)

៣៨-លោក ស៊ុន សិរីវុធ មន្ត្រី ក.ក.ច.ន.យ